# ផែនការសកម្មភាពតំបន់អាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

## I_សេចក្តីផ្តើម:

ដោយស្របគ្នាទៅនឹងបណ្តាលិខិតុបករណ៍អាស៊ានដែលពាក់ព័ន្ធ និង ផែនទីបង្ហាញផ្លូវសម្រាប់**សហគមន៍អាស៊ាន**ទាក់ទងនឹងអំពើជួញដូរមនុស្សដែរ ដែលតម្រូវការចាំបាច់ឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិឱ្យបានខ្លាំងក្លា និងយុទ្ធសាស្ត្រតំបន់មួយដ៏គ្រប់ជ្រុងជ្រោយ ដើម្បីបង្ការ-ទប់ស្កាត់ បង្ក្រាប និងដាក់ទោសនូវរាល់គ្រប់ទម្រង់ទាំងអស់នៃអំពើជួញដូរមនុស្សរួមមាន អំពើជួញដូរផ្លូវភេទ អំពើជួញដូរពលកម្ម និងអំពើជួញដូរសរីរាង្គ ជាពិសេសស្ត្រី និងកុមារ។ ផែនការសកម្មភាពតំបន់នេះ សំដៅបំពេញឱ្យ**អនុសញ្ញាអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ** (ACTIP) មានគោលបំណងផ្តល់នូវផែនការសកម្មភាពជាក់លាក់ទៅក្នុងច្បាប់ប្រទេស និងគោលនយោបាយរបស់ បណ្តារដ្ឋ**សមាជិកអាស៊ានទាំងអស់** ក៏ដូចជាកាតព្វកិច្ចអន្តរជាតិដែលពាក់ព័ន្ធនានា សំដៅដោះស្រាយប្រកបដោយប្រសិទ្ធិភាពនូវបណ្តាបញ្ហាប្រឈមថ្នាក់តំបន់ដែលជាបញ្ហារួមរបស់បណ្តារដ្ឋ**សមាជិកអាស៊ានទាំងអស់**និងជាបញ្ហាកង្វល់ដ៏ចំបងដែលកំពុងកើតមាន ពោលគឺៈ(១)-ការបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស (២)-កិច្ចការពារជនរងគ្រោះ (៣)-ការអនុវត្តច្បាប់ និងការផ្តន្ទាទោសបទល្មើសជួញដូរមនុស្ស និង(៤)-កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលតំបន់ និងអន្តរជាតិ។

ដើម្បីអនុវត្តផែនការសកម្មភាពតំបន់នេះ បណ្តា**រដ្ឋជាសមាជិកអាស៊ាន**ទាំងអស់សុទ្ធតែបានគិតគូរអំពីសិទ្ធិស្មើភាពគ្នា និងសេចក្តីថ្លៃថ្នូរនៃមនុស្សមិនអាចកាត់ផ្តាច់បានរបស់ស្ត្រី បុរស ក៏ដូចជាសិទ្ធិរបស់កុមារដូចបានឆ្លុះបញ្ចាំងនៅក្នុងបណ្តាលិខិតុបករណ៍អន្តរជាតិ និងតំបន់ និងនៅក្នុងចំណោមបណ្តាលិខិតុបករណ៍ផ្សេងទៀតដូចខាងក្រោមៈ

១. **ធម្មនុញ្ញរបស់សមាគមន៍នៃបណ្តាប្រជាជាតិនៅអាស៊ីអាគ្នេយ៍ (ធម្មនុញ្ញអាស៊ាន)**
២. **អនុសញ្ញាសហប្រជាជាតិ ស្តីពី ឱ្យក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង និងពិធីសារដើម្បីបង្ការ-ទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ**
៣. **អនុសញ្ញា ស្តីពីសិទ្ធិកុមារ (CRC)**
៤. **អនុសញ្ញា ស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW)**
៥. **ផែនការសកម្មភាពសាកលរបស់សហប្រជាជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស**

៦. **សេចក្តីប្រកាសអាស៊ាន ស្តីពីសិទ្ធិមនុស្ស**

៧. **សេចក្តីប្រកាសអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ អនុម័តកាលពីឆ្នាំ ២០០៤**

៨. **ការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចំពោះអំពើជួញដូរមនុស្ស : បញ្ចប់និទណ្ឌភាពសម្រាប់ពួកជួញដូរ និងធានាផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ឆ្នាំ២០០៧ ( “*គោលការណ៍ណែនាំអាស៊ានសម្រាប់អ្នកអនុវត្តផ្ទាល់*”)**

៩. **សេចក្តីថ្លែងការណ៍រួមរបស់មេដឹកនាំអាស៊ាន ស្តីពីការលើកកំពស់កិច្ចសហប្រតិបត្តិការប្រឆាំងនឹងអំពើជួញដូរមនុស្សនៅអាស៊ីអាគ្នេយ៍ ឆ្នាំ ២០១១ និង**

**១០.ផែនការសកម្មភាពអាស៊ាន ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន**

## II_បញ្ហាប្រឈម:

ផ្អែកលើ**អនុសញ្ញារបស់សហប្រជាជាតិ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង** និង **ពិធីសារដើម្បីបង្ការ-ទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ជាទូទៅគេឃើញមានអំពើជួញដូរមនុស្សចំនួន ០៣ ប្រភេទ។ ទាំងបីប្រភេទនេះរួមមាន អំពើជួញដូរផ្លូវភេទ អំពើជួញដូរពលកម្ម និងអំពើជួញដូរសរីរាង្គ។** រដ្ឋជាសមាជិកអាស៊ានមួយចំនួនមិនបានចាត់ទុកគ្រប់អំពើជួញដូរទាំងបីប្រភេទនេះជាអំពើល្មើសច្បាប់នោះឡើយ ទន្ទឹមនឹងនោះប្រទេសខ្លះពុំទាន់បានអនុម័តច្បាប់ដោយឡែក ស្តីពី អំពើជួញដូរមនុស្សនៅឡើយទេ ។

ស្របពេលជាមួយគ្នានេះដែរ ប្រទេសអាស៊ានមួយចំនួនត្រូវបានចាត់ទុកជាប្រទេសគោលដៅ ក្នុងខណៈដែលប្រទេសជាសមាជិកដទៃទៀតត្រូវបានចាត់ទុកជាប្រទេសប្រភព ឬ ប្រទេសឆ្លងកាត់(សំចត)។ បណ្តា**រដ្ឋជាសមាជិកអាស៊ាន**ទាំងអស់សុទ្ធតែមានបណ្តាបញ្ហាប្រឈម បណ្តាអាទិភាព និង បណ្តាយុទ្ធសាស្ត្រជាតិផ្សេងៗគ្នា គឺអាស្រ័យដោយពួកគេជាប្រទេសប្រភព ប្រទេសឆ្លងកាត់ ឬ ជាប្រទេសគោលដៅ។ បើទោះជាយ៉ាងនេះក្តី ពួកគេសុទ្ធតែមានផលប្រយោជន៍រួម និងការប្តេជ្ញាចិត្តរួមដូចគ្នានៅក្នុងការបង្ការ-ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

*បណ្តាបញ្ហាប្រឈមរួមនៅក្នុងបណ្តារដ្ឋជាសមាជិកអាស៊ាន រួមមាន :*

១. កាត់បន្ថយកត្តាទាំងឡាយដែលធ្វើឱ្យមនុស្ស ជាពិសេសស្ត្រី និងកុមារងាយទទួលរងគ្រោះដោយអំពើជួញដូរ ដូចជា ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង អំពើពុករលួយរបស់រដ្ឋាភិបាល ភាពក្រីក្រ កំរិតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមមានភាពខុសគ្នា អស្ថិរភាពសេដ្ឋកិច្ច ការអនុវត្តច្បាប់ និង ប្រព័ន្ធច្បាប់ពុំមានប្រសិទ្ធិភាព និង ការទប់ស្កាត់តម្រូវការដែលផ្គត់ផ្គង់រាល់ទម្រង់នៃអំពើធ្វើអាជីវកម្មលើមនុស្សជាពិសេសស្ត្រី និងកុមារ ដែលនេះជាហេតុនាំឱ្យកើតមានអំពើជួញដូរ ។

២. មានច្បាប់សមស្រប ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធិភាព

៣. តម្រូវការដើម្បីលើកកំពស់សមត្ថភាពរបស់មន្រ្តីអនុវត្តច្បាប់នៅជួរមុខ ក្នុងគោលបំណងរកឃើញទាន់ពេល និង ទប់ស្កាត់ការបំលាស់ទីជនរងគ្រោះដោយអំពើជួញដូរចេញពីប្រទេសប្រភព ឆ្លងចូលតាមប្រទេសឆ្លងកាត់រួចទៅកាន់ប្រទេសគោលដៅ ។

៤. ការកំណត់អត្តសញ្ញាណជនរងគ្រោះបានត្រឹមត្រូវ និង ផ្តល់កិច្ចការពារសមស្របដល់ពួកគេ

៥. តម្រូវការចាំបាច់ដល់ការកែលម្អការស៊ើបអង្កេត និងការផ្តន្ទាទោសពួកជួញដូរ ជាពិសេសចំពោះករណីរឿងទាំងឡាយដែលមានលក្ខណៈស្មុគស្មាញ ។

៦. តម្រូវការចាំបាច់ដើម្បីលើកកំពស់ការទំនាក់ទំនង និងសម្របសម្រួលផ្ទាល់ រវាង និង ក្នុងចំណោមបណ្តាអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តារដ្ឋជាសមាជិកអាស៊ាន និង

៧. កង្វះខាតយន្តការច្បាប់តំបន់ប្រកបដោយប្រសិទ្ធិភាព និងបណ្តាយន្តការផ្សេងទៀត ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ។

## III_គោលបំណង:

បណ្តារដ្ឋជាសមាជិកអាស៊ានទាំងអស់ព្យាយាមដោះស្រាយរាល់បញ្ហាប្រឈមទាំងនេះប្រកបដោយប្រសិទ្ធិភាពដើម្បីបង្ការ-ទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសរាល់ទម្រង់នៃអំពើជួញដូរមនុស្សឱ្យមានភាពរីកចំរើនជាលំដាប់ក្នុងនោះរួមមានទាំងកិច្ចការពារ និងផ្តល់ជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរនៅក្នុងតំបន់ និងព្យាយាមធ្វើការ

ឆ្ពោះទៅរកយុទ្ធសាស្ត្រតំបន់មួយដ៏គ្រប់ជ្រុងជ្រោយ និងមានលក្ខណៈសម្របសម្រួលកាន់តែប្រសើរឡើង ដើម្បីសម្រេចគោលបំណងនេះ ។

## IV_ផែនការសកម្មភាព

យើងទាំងអស់គ្នា ជាសមាជិកនៃបណ្តារដ្ឋអាស៊ានប្តេជ្ញាប្រែក្លាយឆន្ទៈនយោបាយរបស់ពួកយើងឱ្យទៅជាកម្មភាពពិតជាក់ស្តែងស្តែង តាមរយៈការអនុម័តផែនការសកម្មភាព សំដៅ :

១. ពង្រឹងនីតិរដ្ឋ និងការត្រួតពិនិត្យព្រំដែននៅក្នុងចំណោមបណ្តារដ្ឋជាសមាជិកអាស៊ានទាំងអស់ ។

២. បង្កើនកិច្ចខិតខំនានាដើម្បីផ្តន្ទាទោសបណ្តាករណីរឿងជួញដូរមនុស្សឱ្យបានកាន់តែខ្លាំងក្លាឡើង និង

៣. ពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ ដោយផ្អែកលើស្មារតីទទួលខុសត្រូវរួម សំដៅដោះស្រាយប្រកបដោយប្រសិទ្ធិភាពរាល់តម្រូវការ និងការផ្តាច់ផ្តង់ដល់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ដែលជាហេតុនាំឱ្យកើតមានអំពើជួញដូរ ជាពិសេសស្ត្រី និងកុមារ ។

## ក-ការបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស

**ក.**បង្កើនយុទ្ធនាការលើកកំពស់ការយល់ដឹង ដើម្បីអប់រំមនុស្សគ្រប់ជាន់ថ្នាក់នៅក្នុងសង្គម អំពីអំពើជួញដូរមនុស្ស និងការរំលោភលើសិទ្ធិមនុស្សដែលជាប់ទាក់ទង ដោយសំដៅទៅលើក្រុមមនុស្សទាំងឡាយដែលមានហានិភ័យខ្លាំងបំផុត ដោយត្រូវគួបផ្សំជាមួយនឹងការចូលរួមពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន បណ្តាអង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងថ្នាក់ដឹកនាំសហគមន៍ ។

ខ. បន្តការកសាងសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ អន្តោប្រវេសន៍ អប់រំ សង្គមកិច្ច ការងារ និងមន្ត្រីពាក់ព័ន្ធផ្សេងទៀត ក្នុងការបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស ដោយត្រូវធ្វើការពិចារណាដល់តម្រូវការនៃការគោរពសិទ្ធិមនុស្ស និងបណ្តាបញ្ហារសើបនៃកុមារ និងយេនឌ័រ និងតាមកាលៈទេសៈសមស្របត្រូវជំរុញលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការជាមួយសង្គមស៊ីវិល បណ្តាអង្គការក្រៅរដ្ឋាភិបាល និងបណ្តាអង្គការពាក់ព័ន្ធផ្សេងទៀត[៤] ។

*បកប្រែក្រៅផ្លូវការដោយ លោក ឧត្តមសេនីយ៍ត្រី សុខ រស្មី*

គ. រៀបចំឱ្យមានយន្តការនានាប្រកបដោយប្រសិទ្ធិភាព និងធានាដល់ការអនុវត្តយន្តការទាំងនោះបានត្រឹមត្រូវដើម្បីបង្ការ-ទប់ស្កាត់ការបំលាស់ទីរបស់ពួកជួញដូរ និងជនរងគ្រោះឱ្យមានប្រសិទ្ធភាពតាមរយៈប្រព័ន្ធត្រួតពិនិត្យព្រំដែន ការចេញឯកសារអត្តសញ្ញាណ និង ឯកសារធ្វើដំណើរបានត្រឹមត្រូវ និងតាមរយៈបណ្ដាវិធានការបង្ការ-ទប់ស្កាត់ការក្លែងបន្លំ ការក្លែងក្លាយ ឬ ការប្រើប្រាស់ឯកសារអត្តសញ្ញាណ និងឯកសារធ្វើដំណើរបែបលួចបន្លំ និង

ឃ.បង្កើនកិច្ចសហប្រតិបត្តិការឆ្លងដែន និងការចែករំលែកព័ត៌មានសំងាត់ និងព័ត៌មានចំហ សំដៅបន្ទុចបង្អាក់ប្រតិបត្តិការរបស់ពួកជនជួញដូរ ។

ង. អនុម័ត និងអនុវត្តច្បាប់ការងារ និងបណ្ដាយន្តការផ្សេងទៀតបានសមស្រប សំដៅលើកស្ទួយ និងការពារផលប្រយោជន៍ និងសិទ្ធិរបស់កម្មករ ដើម្បីកាត់បន្ថយហានិភ័យរបស់ពួកគេឱ្យចៀសផុតពីការជួញដូរ ។

ច. អនុម័ត និងធានាចំពោះការអនុវត្តផែនការសកម្មភាពជាតិ បើអាចធ្វើទៅបាន ត្រូវដាក់ចេញ និងផ្ដល់អាទិភាពដល់បណ្ដាគោលនយោបាយ និងកម្មវិធីសំខាន់ៗ ក្នុងគោលបំណងបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស និងដើម្បីពង្រឹងការអនុវត្ត សម្របសម្រួល ព្រមទាំងយន្តការតាមដានផែនការទាំងនេះ ។

ឆ. អនុវត្ត ឬ គាំទ្រដល់ការសិក្សាស្រាវជ្រាវអំពីបណ្ដាប្រធានបទពាក់ព័ន្ធនានា ដែលបណ្ដា**រដ្ឋជាសមាជិកអាស៊ាន**ទាំងអស់ត្រូវយកមកប្រើប្រាស់ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និង ប្រមូលទិន្នន័យសមស្របដើម្បីផ្ដល់លទ្ធភាពដល់ការធ្វើវិភាគ និង ការយល់ដឹងបានកាន់តែប្រសើរឡើងអំពីចរិតលក្ខណៈ និង វិសាលភាពនៃអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និង ថ្នាក់តំបន់ ។

ជ. កសាងប្រព័ន្ធប្រមូលទិន្នន័យជាតិទាក់ទងនឹងអំពើជួញដូរមនុស្ស និងវិធីសាស្ត្រនៃការផ្លាស់ប្តូរទិន្នន័យទាំងនេះ រវាង និងក្នុងចំណោមបណ្តារដ្ឋជាសមាជិកអាស៊ាន ក្នុងគោលបំណងបង្កើតប្រព័ន្ធទិន្នន្នដ្ឋានតំបន់មួយសម្រាប់អំពើជួញដូរមនុស្ស។

ឈ. ប្រើប្រាស់បណ្តាគោលការណ៍ណែនាំតំបន់ដែលនៅជាធរមាន ក៏ដូចជាកសាង ឬពង្រឹងបណ្តាគោលការណ៍ណែនាំជាតិសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះ ក្នុងនោះរួមមានការអនុវត្តបណ្តាវិធានការសមស្របនានា ដោយមិនរើសអើង ដែលធ្វើដូចនេះនឹងជួយដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្នុងចំណោមក្រុមមនុស្សដែលងាយរងគ្រោះដោយអំពើជួញដូរ។ ក្នុងនោះការឆាប់រកឃើញបណ្តាករណីទាំងឡាយ ដែលអាចជាករណីជួញដូរមនុស្សនឹងអាចធ្វើឱ្យការឆ្លើយតបបានរួសរាន់ដើម្បីបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស និងកាត់បន្ថយការធ្វើអាជីវកម្មលើជនរងគ្រោះជានជាអតិបរមា។

ញ.បង្កើន និង គាំទ្រកិច្ចប្រឹងប្រែងលើការបង្ការ-ទប់ស្កាត់នៅក្នុង**រដ្ឋជាសមាជិកអាស៊ាន**នីមួយៗដោយត្រូវផ្តោតទៅលើការទប់ស្កាត់ទាំងតម្រូវការ និង ការផ្គត់ផ្គង់ដែលបណ្តាលឱ្យមានការធ្វើអាជីវកម្មលើមនុស្ស និងជាហេតុនាំឱ្យកើតមានអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។

ដ. ក្នុងករណីជួញដូរមនុស្សឆ្លងដែនវិញ ត្រូវរិះរកវិធីដែលប្រទេសប្រភពអាចអនុវត្តបណ្តាវិធានការបង្ការ-ទប់ស្កាត់ប្រកបដោយប្រពលលក្ខណៈ ដោយត្រូវធ្វើសហប្រតិបត្តិការជាមួយ**ភាគី**ទទួលដែលជាអ្នកអាចផ្តល់ព័ត៌មានដ៏មានសារៈប្រយោជន៍ ដែលប្រមូលបានមកពីជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង

ឋ. ពង្រឹងបណ្តាវិធានការបង្ការ ដើម្បីទប់ស្កាត់តម្រូវការដែលផ្គត់ផ្គង់ដល់រាល់ទម្រង់នៃការធ្វើអាជីវកម្មលើមនុស្ស ជាហេតុនាំឱ្យកើតមានអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ក្នុងនោះរួមមានកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សមិនឱ្យទទួលរងគ្រោះសារជាថ្មីម្តងទៀត ជាពិសេស ស្ត្រី និងកុមារ។

## ខ-កិច្ចការពារជនរងគ្រោះ

ក. បញ្ជាក់អះអាងសារជាថ្មីថា ការលើកស្ទួយ និងការការពារសិទ្ធិមនុស្សរបស់ជនរងគ្រោះដោយអំពើជួញដូរទាំងអស់ និងការអនុវត្តបណ្តាវិធានការប្រកបដោយប្រសិទ្ធិភាពដើម្បីឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស គឺជាកិច្ចការដែលត្រូវបំពេញបន្ថែម និងជួយពង្រឹងគ្នាទៅវិញទៅមក ។

ខ. បន្តការអភិវឌ្ឍន៍កិច្ចគាំពារ ការការពារ និងការគាំទ្រឱ្យបានសមស្របសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អនុលោមតាមមាត្រា **VI** (១០) របស់ **ACTIP** ។

គ.ផ្តល់បណ្តាសេវាកម្មឯកទេសនានាដល់ជនរងព្រោះដោយអំពើជួញដូរមនុស្ស ដែលគេបានកំណត់អត្តសញ្ញាណរួច ឱ្យស្របតាម**អនុសញ្ញាអាស៊ានប្រឆាំងនឹងអំពើជួញដូរមនុស្ស** និងបណ្តាលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធផ្សេងទៀត ក្នុងនោះរួមមាន ការទទួលបានសេវាសុខភាព ក្នុងគោលបំណងបង្ការទប់ស្កាត់ ការព្យាបាល ការថែទាំ និងសេវាគាំទ្រសម្រាប់ជម្ងឺហ៊ីវ និងអេដស៍ និងជម្ងឺដែលកើតពីការឆ្លងតាមឈាម និងជម្ងឺឆ្លងផ្សេងទៀតសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទាំងឡាយណាដែលទទួលរងការធ្វើអាជីវកម្មផ្លូវភេទ ដោយត្រូវពិចារណាដល់ហេតុការណ៍នៃការជួញដូរមនុស្សក្នុងគោលបំណងយកទៅធ្វើអាជីវកម្មផ្លូវភេទ ជាហេតុបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពធ្ងន់ធ្ងរចំពោះមុខ និងរយៈពេលយូរ ក្នុងនោះរួមទាំងសុខភាពផ្លូវភេទ និងសុខភាពនៃការបន្តពូជ ។

ឃ.អនុលោមតាមច្បាប់ វិធាន បទបញ្ញត្តិ/បទបញ្ជា និងបណ្តាគោលនយោបាយប្រទេសរបស់ខ្លួន និងអាស្រ័យដោយករណីសមស្របនានា ត្រូវពិចារណាមិនដាក់ឱ្យជនរគ្រោះដោយអំពើជួញដូរមនុស្សទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬផ្នែករដ្ឋបាល នូវអំពើខុសច្បាប់នានាដែលពួកគេបានប្រព្រឹត្ត ប្រសិនបើអំពើទាំងនោះមានការពាក់ពន្ធ័ដោយផ្ទាល់ទៅនឹងអំពើជួញដូរមនុស្ស ។

ង.ធានាផ្តល់លទ្ធភាពជូនជនរងគ្រោះដោយអំពើជួញដូរ ដោយត្រូវយកចិត្តទុកដាក់ជាពិសេសដល់កុមារក្នុងនោះត្រូវផ្តល់កិច្ចការពារ ជំនួយឧបត្ថម្ភ និងសេវាកម្មនានាសម្រាប់ស្តារឡើងវិញផ្នែករាងកាយចិត្តសាស្ត្រ សង្គម និងការស្តារនីតិសម្បទា ដោយត្រូវធ្វើសហប្រតិបត្តិការជាមួយបណ្តាអង្គការ

ក្រៅរដ្ឋាភិបាល និងបណ្តាអង្គការពាក់ព័ន្ធផ្សេងទៀត និងបណ្តាផ្នែកសង្គមស៊ីវិលទៅតាមលក្ខណៈសមស្រប ដូចជាការបង្កើតបណ្តាញអ្នកផ្តល់សេវា ដើម្បីផ្តល់ការថែទាំផ្នែកវេជ្ជសាស្ត្រ ការពិគ្រោះយោបល់ ការអប់រំ និងឱកាសទទួលបានការបណ្តុះបណ្តាល ជំនួយផ្នែកច្បាប់ និងសេវាបកប្រែភាសា។

ច. បង្កើត និងប្រើប្រាស់នូវនីតិវិធីសមស្របសំរាប់ការសង្គ្រោះ កិច្ចការពារ ការស្តារឡើងវិញ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គមគ្រួសារ និងសហគមន៍ អនុលោមតាមច្បាប់ប្រទេស ដោយត្រូវយកចិត្តទុកដាក់ជាពិសេសដល់ជនរងគ្រោះជាកុមារ។

ឆ. ធានាថា ប្រព័ន្ធច្បាប់ ឬ រដ្ឋបាលក្នុងប្រទេសរួមបញ្ចូលនូវបណ្តាវិធានការនានា សំដៅផ្តល់ព័ត៌មានដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅតាមភាសាដែលពួកគេអាចយល់បាន ស្តីអំពីសិទ្ធិស្របច្បាប់ និងនីតិវិធីតុលាការ និងរដ្ឋបាលដែលពាក់ព័ន្ធ និងជួយសម្រួលឱ្យពួកគេបានទទួលជំនួយដើម្បីបង្កលក្ខណៈឱ្យពួកគេបញ្ចេញទស្សនៈ និងបង្ហាញពីទុក្ខកង្វល់របស់ពួកគេ និងទទួលបានការយកទៅគិតគូរពិចារណានៅគ្រប់ដំណាក់កាលសមស្របនៃនីតិវិធីរឿងក្តីទាំងនេះប្រឆាំងនឹងជនល្មើសដោយពុំបង្កឱ្យមានព្យសនកម្មដល់សិទ្ធិការពារក្តី អនុលោមតាម **ACTIP**។

ជ. ទទួលស្គាល់នូវតួនាទីដ៏មានសារៈសំខាន់របស់បណ្តាអង្គការសង្គមស៊ីវិល នៅក្នុង**រដ្ឋជាសមាជិកអាស៊ាន**នីមួយៗ ក្នុងការផ្តល់ជំនួយ និងផ្តល់អំណាចដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងការជួយដល់ពួកគេដើម្បីស្វែងរកសំណង និងជួយសម្របសម្រួលដល់ការថែទាំ និងផ្តល់សេវាសមស្របដល់ជនរងគ្រោះ ក្នុងនោះរួមមានកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជិតស្និតជាមួយមន្ត្រីអនុវត្តច្បាប់។

## គ- ការអនុវត្តច្បាប់ និង ការផ្តន្ទាទោសបទល្មើសជួញដូរមនុស្ស

ក. ចាត់ទុកអំពើជួញដូរមនុស្សជាបទល្មើសព្រហ្មទណ្ឌ អនុលោមតាមមាត្រា **IV** នៃ **ACTIP**។

ខ. បង្កើតនូវវិធីសាស្ត្រស៊ើបអង្កេតបុរេសកម្ម ហើយបើមានលទ្ធភាព ត្រូវធ្វើការតាមឃ្លាំមើល និង អនុវត្តបណ្តាវិធានការបុរេសកម្មផ្សេងទៀតដើម្បីប្រមូលភស្តុតាងមកបញ្ជាក់លើករណីរឿង ដើម្បីធ្វើការផ្តន្ទាទោសបណ្តាករណីរឿងជួញដូរមនុស្ស បើទោះជាពុំមានការផ្តល់សក្ខីកម្មពីជនរងគ្រោះក៏ដោយ ។

គ. លើកកំពស់កិច្ចខិតខំ ដើម្បីធ្វើការស៊ើបអង្កេតបណ្តាករណីសង្ស័យថាជាករណីជួញដូរមនុស្ស ពង្រឹងបណ្តាមធ្យោបាយនានាដើម្បីប្រយុទ្ធប្រឆាំង និង ផ្តន្ទាទោសពួកជនប្រព្រឹត្តបទល្មើស ក្នុងនោះរួមបញ្ចូលទាំងការអនុវត្តតាមរយៈការប្រើប្រាស់នូវការបង្កកទ្រព្យសម្បត្តិជាលក្ខណៈប្រព័ន្ធក្នុងគោលបំណងទុករឹបអូសជាយថាហេតុ ស្របតាមបណ្តាបទបញ្ញត្តិនានានៃមាត្រា ១៧ របស់ **ACTIP** ។

ឃ.តែងតាំងព្រះរាជអាជ្ញាឯកទេស និង បង្កើតអង្គភាពអយ្យការឯកទេសសំរាប់ទទួលបន្ទុកដោះស្រាយបណ្តាករណីរឿងជួញដូរមនុស្ស តាមលទ្ធភាពដែលអាចធ្វើទៅបាន ។

ង.ផ្តន្ទាទោសបណ្តាបទល្មើសជួញដូរមនុស្សទាំងឡាយ ដោយត្រូវរួមបញ្ចូលគ្រប់ទម្រង់នៃអំពើធ្វើអាជីវកម្ម និងអនុម័តព្រមទាំងអនុវត្ត និង ពង្រឹងច្បាប់ ដែលចាត់ទុកអំពើជួញដូរមនុស្សគ្រប់ទម្រង់/រូបភាពជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ ពិសេសអំពើដែលប្រព្រឹត្តចំពោះស្ត្រី និងកុមារ ។

ឆ.ប្រយុទ្ធប្រឆាំង និងផ្តន្ទាទោសក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ដែលធ្វើសកម្មភាពជួញដូរមនុស្ស អនុលោមតាមច្បាប់របស់ប្រទេស ។

ជ. ស៊ើបអង្កេត ផ្តន្ទាទោស និងដាក់ទោសមន្ត្រីសាធារណៈដែលពុករលួយ ដែលចូលរួមក្នុង ឬ ជួយសំរួលដល់អំពើជួញដូរមនុស្ស និង លើកស្ទួយគោលនយោបាយគ្មានការអត់ឱនចំពោះមន្ត្រីពុករលួយ ស្របតាមអនុសញ្ញាសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ និងអនុសញ្ញាសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ។

ឈ.បន្តការកសាងយន្តការការពារសមស្រប និង ប្រកបដោយប្រសិទ្ធិភាពសម្រាប់សាក្សីនៃអំពើជួញដូរ តាមលទ្ធភាពអាចធ្វើទៅបាន ។

ញ.ធានាដាក់ឱ្យជនប្រព្រឹត្តបទល្មើសជួញដូរមនុស្សគ្រប់ប្រភេ ទទទួលខុសត្រូវចំពោះទង្វើទាំងឡាយដែលខ្លួនបានប្រព្រឹត្ត ក្នុងនោះរួមទាំងការទទួលខុសត្រូវផ្នែកនីតិបុគ្គល ស្របតាម **ACTIP** ។

**ដ**. តាមលទ្ធភាពដែលច្បាប់របស់ប្រទេសអនុញ្ញាតឱ្យ លើកលែងប្រាក់បង់ថ្លៃអន្តោប្រវេសន៍ ដើម្បីសម្របសម្រួលដល់ការចូល និង ការស្នាក់នៅបណ្ដោះអាសន្នរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្នុងដែនដីនៃរដ្ឋជាសមាជិកអាស៊ាន ក្នុងគោលបំណងផ្ដល់សក្ខីកម្ម ឬ មូលហេតុផ្សេងទៀត ដើម្បីធ្វើសហប្រតិបត្តិការក្នុងការផ្ដន្ទាទោសពួកជួញដូរមនុស្ស ។

**ឋ**. ធ្វើប្រពលលក្ខណៈលើការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ព្រះរាជអាជ្ញា ចៅក្រម មន្ត្រីអន្តោប្រវេសន៍ មន្ត្រីទទួលបន្ទុកកិច្ចការបរទេស អធិការកិច្ចការងារ មន្ត្រីសង្គមកិច្ច និង បុគ្គលិកដទៃទៀតដែលពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ។

**ឌ**.ពង្រឹងការចែករំលែកព័ត៌មាន ដំណើរការស៊ើបអង្កេត និងការផ្ដន្ទាទោសរឿងក្ដីជួញដូរមនុស្ស ក្នុងនោះរួមទាំងការបង្កើតក្រុមពង្រឹងការអនុវត្តលក្ខណៈឯកទេស លើកទឹកចិត្តឱ្យគ្នា រវាងបណ្ដាទីភ្នាក់ងារជាតិ ពន្លឿនការស៊ើបអង្កេត និងការផ្ដន្ទាទោសបណ្ដាករណីរឿងធ្ងន់ធ្ងរ ឬមានស្ថានទម្ងន់ទោសជាពិសេសនៅកម្រិតតំបន់ ។

## ៥-កិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលតំបន់ និង អន្តរជាតិ

ក.ពង្រឹងយន្តការនៃបណ្ដាប្រធានអង្គភាពឯកទេស (**HSU**) នៅក្នុងក្របខ័ណ្ឌអាស៊ាន ។

ខ. ប្រើប្រាស់បណ្ដាយន្តការអន្តរជាតិដែលមានស្រាប់ ក្នុងនោះរួមទាំងបណ្ដាឧបករណ៍ និង ធនធានរបស់ **INTERPOL** ដូចជាទិន្នន្នានរបស់ **INTERPOL** ។

គ.ពង្រឹងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមបណ្តារដ្ឋជាសមាជិកអាស៊ាន ក្នុងការប្រយុទ្ធប្រឆាំងនឹងបណ្តាឧក្រិដ្ឋកម្ម ដែលអាចមានការពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស រួមទាំងការសំអាតប្រាក់ អំពើពុករលួយ អំពើរត់ពន្ធជនទេសន្តរប្រវេសន៍ និងគ្រប់រូបភាពនៃឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ។

ឃ.ពង្រឹងកិច្ចសហប្រតិបត្តិការលើផ្នែកប្រតិបត្តិការ រវាងបណ្តារដ្ឋជាសមាជិកអាស៊ាន អនុលោមតាមច្បាប់ប្រទេស និងបណ្តាកិច្ចព្រមព្រៀងទ្វេភាគី ឬ ពហុភាគី បើអាចធ្វើទៅបានត្រូវបង្កើតក្រុមស៊ើបអង្កេតរួមគ្នា រវាងបណ្តារដ្ឋជាសមាជិកអាស៊ានដែលពាក់ព័ន្ធ ។

ង. ពង្រឹងសកម្មភាពនៃការកសាងសមត្ថភាព ក្នុងគោលបំណងកែលម្អការរៀបចំ និង ការទទួលសំណើនានាទាក់ទងនឹងជំនួយផ្លូវច្បាប់ទៅវិញទៅមក ការធ្វើបត្យាប័ន និង កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ឆ្លងដែន ដើម្បីបង្ការ-ទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ។

ច. ផ្តល់ឱ្យគ្នាទៅវិញទៅមកនូវវិធានការជំនួយផ្លូវច្បាប់ទៅវិញទៅមកក្នុងរឿងក្តីព្រហ្មទណ្ឌ តាមអស់លទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីធ្វើការផ្តន្ទាទោស និង ដាក់ទោសបទល្មើសជួញដូរមនុស្សស្របតាម**សន្ធិសញ្ញា ស្តីពី ជំនួយផ្លូវច្បាប់ទៅវិញទៅមកក្នុងរឿងក្តីព្រហ្មទណ្ឌនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ានដែលរួមចិត្តតែមួយ និង បណ្តាកិច្ចព្រមព្រៀងទ្វេភាគី** ។

ឆ.ប្រើប្រាស់កិច្ចសហប្រតិបត្តការអន្តរជាតិ ក្នុងនោះរួមទាំងតាមរយៈជំនួយផ្នែកច្បាប់ទៅវិញទៅមក អនុលោមតាមបណ្តាបទបញ្ញត្តិនៃ**សន្ធិសញ្ញា ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ នៅក្នុងចំណោមប្រទេសជាសមជិកអាស៊ានទាំងអស់ដែលរួមចិត្តតែមួយ** និងស្របតាមច្បាប់ និងបទបញ្ញត្តិរបស់**រដ្ឋជាសមាជិកអាស៊ាន**នីមួយៗ ដើម្បីធានាការស៊ើបអង្កេត និងការផ្តន្ទាទោស និងការរឹបអូសទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធិភាព ។

ជ.ពង្រឹង និងបង្កើនកិច្ចសហការ និងការសម្របសម្រួល នៅក្នុងចំណោមបណ្ដាវេទិកាអាស៊ានដែលបង្កលក្ខណៈដល់ការសម្របសម្រួលកិច្ចសហប្រតិបត្តិការ នៅក្នុងចំណោមបណ្ដារដ្ឋជាសមាជិកអាស៊ានទាំងក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ក្នុងនោះរួមទាំង**ក្រុមការងារទទួលបន្ទុកអំពើជួញដូរមនុស្សរបស់កិច្ចប្រជុំឧត្តមមន្ត្រីអាស៊ាន ស្ដីពីឧក្រិដ្ឋកម្មឆ្លងដែន**(SOMTC) ចំណុះឱ្យ**កិច្ចប្រជុំឧត្តមមន្ត្រីអាស៊ាន ស្ដីពី ឧក្រិដ្ឋកម្មឆ្លងដែន** និង**កិច្ចប្រជុំប្រធានអង្គភាពឯកទេស**(HSU) ដោយត្រូវគិតពិចារណាដល់ការងារពាក់ព័ន្ធដែលអនុវត្តដោយបណ្ដាស្ថាប័នផ្សេងទៀតចំណុះឱ្យស្ថាប័ន**អាស៊ាន**។

ឈ.ជំរុញកិច្ចសហការផ្ដល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ជាមួយបណ្ដាដៃគូពិភាក្សារបស់អាស៊ាន និងជាមួយបណ្ដាអង្គការអន្តរជាតិ តំបន់ និងអនុតំបន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ក្នុងនោះរួមទាំងតាមរយៈការផ្ដល់ជំនួយបច្ចេកទេស និងជំនួយមូលនិធិប្រកបដោយនិរន្តរភាពពីបណ្ដាដៃគូពិភាក្សា និងបណ្ដាអង្គការពាក់ព័ន្ធនានា ក្នុងគោលបំណងពង្រឹងសមត្ថភាពជាសមូហភាព និងជាឯកកត្តជននៃបណ្ដា**រដ្ឋជាសមាជិកអាស៊ាន**ទាំងអស់ ក្នុងការប្រយុទ្ធប្រឆាំងនឹងរាល់គ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស។

ញ. លើកស្ទួយកិច្ចសហប្រតិបត្តិការជាមួយបណ្ដាទីភ្នាក់ងារសហប្រជាជាតិដែលពាក់ព័ន្ធ និងបណ្ដាអង្គការអន្តរជាតិផ្សេងទៀត ដែលទទួលបន្ទុកអំពើជួញដូរមនុស្ស សំដៅពង្រឹងសមត្ថភាពតំបន់ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និង ផ្ដល់ជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព។

ដ. កែលម្អការកសាងសមត្ថភាព ដែលត្រូវចាត់ទុកបញ្ហានេះជាសមាសធាតុសំខាន់ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និង លើកទឹកចិត្ត ព្រមទាំងលើកកំពស់កិច្ចសម្របសម្រួល និងការផ្សារភ្ជាប់គ្នានៅក្នុងអាស៊ាន។

១-តែងតាំងជនបង្គោល ដើម្បីសម្របសម្រួលការទំនាក់ទំនង ការចែករំលែកទិន្នន័យ និងផ្លាស់ប្ដូរព័ត៌មាន ស្ដីពីអំពើជួញដូរមនុស្ស សំដៅពង្រឹងគោលនយោបាយ

*បកប្រែក្រៅផ្លូវការដោយ លោក ឧត្តមសេនីយ៍ត្រី សុខ វណ្ណី*

និងបណ្តាកម្មវិធី ស្តីពីការបង្ការ-ទប់ស្កាត់ និងកិច្ចការពារនៅក្នុងចំណោមបណ្តារដ្ឋជាសមាជិកអាស៊ាន ។

២-លើកស្ទួយកិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលនៅក្នុងចំណោមបណ្តាស្ថាប័ន បណ្តាអង្គការសង្គមស៊ីវិល បណ្តាផ្នែកឯកជន ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និង បណ្តាដៃគូសហការពាក់ព័ន្ធទាំងអស់ សំដៅពង្រឹងគោលនយោបាយ និង បណ្តាកម្មវិធី ស្តីពី ការបង្ការ-ទប់ស្កាត់ និងកិច្ចការពារ ។

ឋ. លើកកំពស់ និង បន្តកសាងបណ្តាគោលការណ៍ណែនាំតំបន់ ស្របតាមបណ្តាគោលការណ៍ជាតិ និងទ្វេភាគីដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស តាមរយៈការពង្រឹងភាពជាដៃគូការសម្របសម្រួល និង កិច្ចសហប្រតិបត្តិការអន្តរជាតិ និង ការអនុវត្តប្រកបដោយប្រសិទ្ធិនូវបណ្តាគោលការណ៍ណែនាំដែលនៅជាធរមាន ។

## V-យន្តការអនុវត្ត

១. ព្យាយាមបញ្ចូលបណ្តាកម្មវិធីពាក់ព័ន្ធ និង សកម្មភាពនៃផែនការសកម្មភាពនេះទៅក្នុងផែនការសកម្មភាពប្រឆាំងនឹងអំពើជួញដូរមនុស្សរបស់បណ្តារដ្ឋជាសមាជិកអាស៊ាននីមួយៗ ដើម្បីធានាបានជោគជ័យ ។

**២.** SOMTC ដោយមានការគាំទ្រពីក្រុមការងារ SOMTC អំពើជួញដូរមនុស្ស នឹងពិនិត្យតាមដានលើការអនុវត្តផែនការសកម្មភាពអាស៊ាននេះ ។

***ធ្វើនៅប្រទេសភីលីពីន*** **ថ្ងៃទី ខែ មេសា ឆ្នាំ ពីរពាន់ ......... មានច្បាប់ដើមជាភាសាអង់គ្លេសតែមួយច្បាប់គត់ ។**

***បកប្រែក្រៅផ្លូវការដោយ លោក ឧត្តមសេនីយ៍ត្រី សុខ វសី្ស***

# សំរាប់ប្រទេសព្រុយណេដារូស្សាឡឹមៈ

(ឈ្មោះជាអក្សរធំ)

(តួនាទី)

*បកប្រែក្រៅផ្លូវការដោយ លោក ឧត្តមសេនីយ៍ត្រី សុខ រស្មី*

*សេចក្តីព្រាងចុងក្រោយ*

សំរាប់ព្រះរាជាណាចក្រកម្ពុជា:

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់សាធារណរដ្ឋឥណ្ឌូណេស៊ីៈ

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវៈ

(ឈ្មោះជាអក្សរធំ)

(តួនាទី)

សំរាប់ម៉ាឡេស៊ីៈ

(ឈ្មោះជាអក្សរធំ)

(តួនាទី)

*បកប្រែក្រៅផ្លូវការដោយលោក* ***ឧត្តមសេនីយ៍ត្រី សុខ រស្មី***

**សំរាប់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា៖**

**(ឈ្មោះជាអក្សរធំ)**

**(តួនាទី)**

**សំរាប់សាធារណរដ្ឋភីលីពីន៖**

**(ឈ្មោះជាអក្សរធំ)**

**(តួនាទី)**

**សំរាប់សាធារណរដ្ឋសឹង្ហបូរី៖**

**(ឈ្មោះជាអក្សរធំ)**

**(តួនាទី)**

**សំរាប់ព្រះរាជាណាចក្រថៃ៖**

**(ឈ្មោះជាអក្សរធំ)**

**(តួនាទី)**

*សេចក្តីព្រាងចុងក្រោយ*

សំរាប់សាធារណរដ្ឋសង្គមនិយមវៀតណាមៈ

(ឈ្មោះជាអក្សរធំ)

(តួនាទី)

*បកប្រែក្រៅផ្លូវការដោយលោក* ***ឧត្តមសេនីយ៍ត្រី សុខ  រស្មី***